# មេរៀនទី ៨៖ ការអស្ចារ្យដំបូងរបស់ព្រះយេស៊ូវ

## យ៉ូហាន ២៖១-១១

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/8rFKubSJzG8

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/prwkKaWBKx0

**គោលបំណង៖** ព្រះយេស៊ូវអាចធ្វើការអស្ចារ្យ

**ខគម្ពីរចងចាំ៖ យ៉ូហាន១:៣** *"គ្រប់របស់ទាំងអស់បានកើតមកដោយសារទ្រង់ ហើយក្នុងបណ្ដារបស់ដែលបានបង្កើតមកទាំងប៉ុន្មាន នោះគ្មានអ្វីណាមួយកើតមកក្រៅពីទ្រង់ឡើយ "*។

**ចំរៀង** ( *យូធូបលីង* )៖

១. ព្រះយើងជាព្រះអស្ចារ្យ https://youtu.be/TU6HfxJXLvQ

២. ព្រះអង្គនៃយើងទ្រង់ខ្លាំងពូកែ https://youtu.be/VvrF94VKKHA

៣. ព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់ https://youtu.be/I-PzUIJ0MVo

**១. អធិស្ឋាន**

**២. ចំរៀង** ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

**៣. ល្បែងកំសាន្ត «តើអ្នកចូលចិត្តភេសជ្ជៈដែរឬទេ?»**



សម្ភារៈដែលត្រូវប្រើមាន៖ កូកា១ដប សំបកកំប៉ុងទឹកដោះគោទឹកសណ្ដែក១ (ចាក់ទឹកដោះគោចេញ ហើយចាក់ កូកាកូឡាចូល) ត្រៀមកែវក្រដាស ឬកែវប្លាស្ទិកតូចៗមួយចំនួន។

១. គ្រូពន្យល់កុមារថា ថ្ងៃនេះយើងនិងរៀនអំពីការអស្ចារ្យ សូមសួរកុមារថាតើពួកគេធ្លាប់បានឃើញ ការអស្ចារ្យដែរឬទេ?(អាចជាពេលដែលកូនធ្លាប់បានឃើញនរណាម្នាក់ បានជាសះស្បើយពីជំងឺ របស់ពួកគេ)

២. តើមនុស្សអាចធ្វើការអស្ចារ្យបានដែរឬទេ ឬក៏មានតែព្រះមួយប៉ុណ្ណោះដែលអាចធ្វើការអស្ចារ្យបាន? សូមពន្យល់កុមារថាមានតែព្រះតែមួយអង្គប៉ុណ្ណោះ ដែលអាចធ្វើការអស្ចារ្យបានពីព្រោះទ្រង់មាន អំណាច។

៣. ហេតុអ្វីបានជាអ្នកគិតថាព្រះយេស៊ូវបានធ្វើការអស្ចារ្យ? ទ្រង់បានធ្វើការអស្ចារ្យដើម្បីបង្ហាញដល់មនុស្សទាំងអស់ថាទ្រង់ជាព្រះរាជបុត្រានៃព្រះ។

៤. សូមសួរកុមារថា នៅពេលដែលប្អូនស្រេកទឹក ប្អូនប្រាកដជាត្រូវរកទឹកអ្វីមកញ៉ាំហើយមែនទេ។ គ្រូចាក់កូកាចូលទៅក្នុងកែវក្រដាសតូចៗឲ្យសិស្សញ៉ាំ។ នៅពេលដែលអស់កូកាពីដប សូមនិយាយប្រាប់កុមារថា ឥលូវយើងអស់កូកាហើយ ប៉ុន្តែយើងនៅមានទឹកដោះគោទឹកសណ្ដែក។



៥. គ្រូចាប់ផ្ដើមចាក់ទឹកដោះគោចូលទៅក្នុងកែវក្រដាសរបស់ពួកគេ ពេលនោះក្មេងៗនឹង ឃើញកូកាកូឡាចេញពីកំប៉ុងទឹកដោះគោទៅវិញ!ពួកគេនឹងនិយាយថា «វ៉ាវ១ អស្ចារ្យណាស់! ខ្ញុំគិតថាវាជា

ទឹកដោះគោតែវាបែរចេញជាកូកាពីក្នុងកំប៉ុងទឹកដោះគោទៅវិញ! តើវាអាចទៅរួចបានយ៉ាងម៉េច?»
ទុកឲ្យកុមារជាអ្នកឆ្លើយ។

៦. សូមពន្យល់កុមារៗថា យើងមិនអាចធ្វើការអស្ចារ្យបាននោះទេ! ប៉ុន្តែព្រះយេស៊ូវអាចធ្វើបាន។

## ៤. ការណែនាំមេរៀន

ដូចដែលយើងបានឃើញទាំងអស់គ្នាហើយថា នៅក្នុងកំប៉ុងទឹកដោះគោទឹកសណ្តែកគឺជាកូកាកូឡា។ មើលទៅដូចជាអស្ចារ្យណាស់មែនទេ! ប៉ុន្តែ តាមពិតទៅវាមិនមែនទេ ព្រោះខ្ញុំ(គ្រូ)ទេតើដែលជាអ្នកចាក់កូកាកូឡាចូល ក្នុងកំប៉ុងទឹកដោះគោទឹកសណ្តែកនោះ។ ប៉ុន្តែព្រះយេស៊ូវអាចធ្វើឲ្យមានការអស្ចារ្យកើតឡើងយ៉ាងពិតប្រាកដបាន។ តើការអស្ចារ្យអ្វីខ្លះដែលប្អូនសង្ឃឹមថាព្រះយេស៊ូវ នឹងធ្វើការនៅក្នុងជីវិតរបស់ប្អូន? (ទុកឱ្យកុមារឆ្លើយ)។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ថ្ងៃមួយនោះព្រះយេស៊ូវបានចូលរួមពិធីមង្គលការមួយ។ នៅក្នុងពិធីមង្គលនោះកូនក្រមុំ និងកូនកំលោះបានផឹកស្រាអស់ដូចជាពួកយើងបានផឹកកូកាអស់អីចឹងដែរ។ នៅជំនាន់នោះ វាជារឿងដ៏គួរឲ្យអាម៉ាស់ណាស់ ដែលនៅក្នុងពិធីមង្គលការមួយអស់ស្រាឲ្យភ្ញៀវផឹកនោះ។ វាដូចជាការដែលអ្នកបានអញ្ជើញភ្ញៀវឲ្យទៅផ្ទះរបស់អ្នក ដើម្បីញុំាអាហារពេលល្ងាច ហើយនៅពេលភ្ញៀវមិនទាន់ទាំងបានញុំាគ្រប់គ្នាស្រាប់តែអស់ម្ហូបបាត់។ នៅពេលនោះ ម្តាយរបស់ព្រះយេស៊ូវបានសុំឲ្យទ្រង់ធ្វើអ្វីម្យ៉ាងចំពោះបញ្ហានេះ។ ព្រះយេស៊ូវមានបន្ទូលទៅអ្នកបម្រើនៅក្នុង **យ៉ូហាន ២៖៧** ថា “ ចូរចាក់ទឹកឲ្យពេញពាងទាំងនេះទៅ គេក៏ចាក់ទឹកពេញដល់មាត់ពាង ” ។

រួចទ្រង់មានបន្ទូលប្រាប់គេថា **យ៉ូហាន ២៖៨** “ ឥឡូវនេះចូរដងយកទៅជូនដល់លោកជាមង្គលការចុះ ” ពួកអ្នកបម្រើក៏ធ្វើតាមអ្វីដែលព្រះយេស៊ូវបានបង្គាប់។ នោះអ្នកដែលមកចូលរួមក៏បាននិយាយថា **យ៉ូហាន ២៖១០** “ មនុស្សទាំងឡាយ គេតែងតែលើកស្រាទំពាំងបាយជូរល្អមកជាមុន លុះកាលបានផឹកជាច្រើនហើយនោះ ទើបលើកស្រាទំពាំងបាយជូរ ដែលមិនសូវល្អមកជាក្រោយ តែនេះអ្នកបានទុក ស្រាទំពាំងបាយ ជូរយ៉ាងល្អ ដរាបដល់ឥឡូវនេះវិញ” ។ តើមានអ្វីកើតឡើង? ព្រះយេស៊ូវបាន ធ្វើឲ្យទឹកក្លាយជាស្រាទំពាងបាយជូរ!

សាកស្រមៃមើលថា នៅពេលនោះតើអ្នកបម្រើមានការភ្ញាក់ផ្អើលប៉ុនណាទៅ? ដោយពួកគេគ្រាន់តែចាក់ទឹកទៅឲ្យភ្ញៀវប៉ុណ្ណោះតែពួកគេបែរជានាំគ្នានិយាយ ថា វាគឺជាស្រាទំពាងបាយជូរទៅវិញ! ព្រះយេស៊ូវបានធ្វើការអស្ចារ្យនេះដើម្បីជួយកូនក្រមុំ និងកូនកំលោះ ហើយទ្រង់ក៏ចង់ បង្ហាញទៅមនុស្សគ្រប់គ្នាថា ទ្រង់ជាព្រះរាជបុត្រារបស់ព្រះដែលមានអំណាចផងដែរ។

នេះជាការអស្ចារ្យដំបូងបំផុតដែលព្រះយេស៊ូវបានធ្វើ ហើយវាធ្វើឲ្យអ្នកជឿលើទ្រង់មានការភ្ញាក់ផ្អើល។ បើទោះជាពេលសព្វថ្ងៃនេះក៏ដោយ នៅពេលណាដែលយើងឮអំពីរឿងនេះ យើងក៏នៅតែគិតថាជារឿងដែលអស្ចារ្យដែរ។ ព្រះអង្គជាព្រះតែមួយគត់ ដែលអាចធ្វើឲ្យមានការអស្ចារ្យកើតឡើងយ៉ាងពិតប្រាកដបាន ។ ការអស្ចារ្យនេះបង្ហាញថា ព្រះយេស៊ូវជាព្រះ!

## ៦. សំនួរពិភាក្សា

១. តើមានអ្វីកើតឡើងនៅក្នុងកម្មវិធីមង្គលការ? ( *ពួកគេអស់ស្រាទំពាងបាយជូរ*)

២. តើនរណាជាអ្នកស្នើសុំឲ្យព្រះយេស៊ូវធ្វើអ្វីមួយសំរាប់បញ្ហានេះ?( *ម្តាយរបស់ព្រះយេស៊ូវ*)
៣. តើព្រះយេស៊ូវបានបានប្រើអ្នកបំរើឲ្យយកអ្វីមកចាក់ទៅក្នុងពាង?(ទឹក)
៤. តើមានរឿងអ្វីកើតឡើងនៅពេលដែលអ្នកមកចូលរួមកម្មវិធីបានផឹកទឹកនោះ?( *គាត់បាននិយាយថាកូនក្រមុំ និងកូនកំលោះបានរក្សាទុកស្រាទំពាំងបាយជូរដ៏ល្អបំផុតមកដល់ពេលនេះ*)
៥. តើមាននរណាអាចគិតអំពីការអស្ចារ្យខ្លះៗដែលយើងត្រូវការឥឡូវនេះបានទេ? ( *ទុកឲ្យកុមារជាអ្នកឆ្លើយ*)
៦. តើប្អូនៗជឿថាព្រះអាចធ្វើការអស្ចារ្យនៅក្នុងជីវិតរបស់ប្អូន ដែលជាមនុស្សធម្មតាទៅជាមនុស្សពិសេស នៅក្នុងភូមិ សហគមន៍ឬប្រទេសទាំងមូលដែរឬទេ? ( *ទុកឲ្យកុមារជាអ្នកឆ្លើយ*)

## ៨. ខគម្ពីរចងចាំ

**យ៉ូហាន ១:៣** "គ្រប់របស់ទាំងអស់បានកើតមកដោយសារទ្រង់ហើយក្នុងបណ្តារបស់ដែលបានបង្កើតមកទាំងប៉ុន្មាន នោះគ្មានអ្វីណាមួយកើតមកក្រៅពីទ្រង់ឡើយ"។

## ៩. ហត្ថកម្ម « កាសែតវេទមន្ត »

សូមបោះពុម្ពក្រដាសកាសែតសម្រាប់កុមារ (មើលនៅខាងក្រោម)
១. ឲ្យកុមារនិយាយប្រាប់មិត្តភក្តិរបស់ពួកគេពីដំណើររឿងដ៏អស្ចារ្យដែល ព្រះយេស៊ូវបានធ្វើការអស្ចារ្យរបស់ទ្រង់ជាលើកដំបូង
២. ពួកគេត្រូវគូសរូបភាពនៅក្នុងប្រអប់( ដូចជារូបភាពដែលមាននៅក្នុងក្រដាសកាសែតផ្សេងៗ)ហើយឲ្យគេសរសេរជាសាច់រឿងខ្លីនៅលើបន្ទាត់ដែលគូសស្រាប់ ដោយពន្យល់ថា តើមានអ្វីដែលបានកើតឡើង ហើយហេតុអ្វីបានជាការនោះមានសារៈសំខាន់។
៣. បន្ទាប់មកកុមារអាចសរសេរពីក្តីស្រមៃនៅថ្ងៃអនាគតរបស់ពួកគេ ដោយទុកចិត្តថាព្រះយេស៊ូវនឹងធ្វើការអស្ចារ្យនៅក្នុងជីវិតរបស់ពួកគេ។

## ១០. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស*)

## ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
ព្រះយេស៊ូវបានធ្វើជាភ្ញៀវក្នុងការចូលរួមអបអរសាទរនៅក្នុងពិធីការនៅស្រុកកាណា នេះបានបង្ហាញពីបំណងប្រាថ្នារបស់ទ្រង់ ដែលព្រះអង្គនិងចូលរួមនៅក្នុងគ្រប់ស្ថានភាពទាំងអស់នៅក្នុងជីវិតរបស់យើងដែលរាប់បញ្ចូលទាំងពេលវេលានៃការអរសប្បាយផងដែរ។ សូមអាន **យ៉ូហាន ២:៨-១០** សារឡើងវិញ។ តើដំណើរដែលទឹកក្លាយជាស្រាទំពាំងបាយជូរយ៉ាងណាដែរ វាដូចជាដំណើរការដែលព្រះបានធ្វើការនៅក្នុងជីវិតរបស់យើងដែរ តើយើងមានទំនាក់ទំនងជាមួយនិងទ្រង់នៅពេលណា? ដូចជាទំនាក់ទំនងរបស់អ្នកកំពុងលូតលាស់ជាមួយនិងព្រះដូច្នេះដែរ, ទ្រង់និងបង្កើតអ្នក, ហើយនិងផ្លាស់ប្រែអ្នកឲ្យ កាន់តែដូចទ្រង់ថែមទៀត។ សូមអធិស្ឋានដោយអរព្រះគុណចំពោះការផ្លាស់ប្រែ ដែលធ្វើឲ្យអ្នករីករាយ ដោយសារទំនាក់ទំនងរបស់អ្នកជាមួយនឹងព្រះមេស្ស៊ី។

# ពត៌មានប្រចាំថ្ងៃនៅកម្ពុជា

## ការអស្ចារ្យដំបូងរបស់ព្រះយេស៊ូវ

______________________________________________

______________________________________________

______________________________________________

______________________________________________

______________________________________________

ក្តីស្រមៃនៅថ្ងៃអនាគត________________________________

______________________________________________